សប្បុរិសធម្មកថា

# ព្រះទេពសត្ថា សួរ-ហាយ ក្រុមជំនុំព្រះត្រៃបិដករៀបរៀង

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

ពេលនេះនឹងសំដែងអំពីសប្បុរស ព្រមទាំងធម៌របស់សប្បុរសដោយសេចក្តីសង្ខេបតាមក្រសែនៃព្រះពុទ្ធដីកានិងអដ្ឋកថា ដើម្បីជាសណ្តាប់នៃពុទ្ធបរិស័ទទាំងឡាយ ដូចសេចក្តីដែលត្រូវសំដែងតទៅនេះ ៗ

ពាក្យថា "អ្នកសប្បុរស" គឺបុគ្គលដែលប្រកបដោយធម៌សុចរិតគ្រប់ត្រៃទ្វារគឺ កាយ វាចា ចិត្ត, ជាអ្នកឃើញប្រយោជន៍ដ៏ធំទូលាយជាសាធារណៈដល់អ្នកដទៃ, មិនឃើញត្រឹមតែប្រយោជន៍ផ្ទាល់ខ្លួនប៉ុណ្ណោះ យ៉ាងនេះជាដើម ហៅថា "អ្នកសប្បុរសយ៉ាងឧក្រិដ្ឋ" ៗ មួយទៀតមនុស្សអ្នកមានចិត្តល្អ មានការប្រព្រឹត្តិរៀបរយត្រូវល្អចំពោះលោកអ្នកមានគុណ, ចំពោះសង្ឃគ្រហស្ថទាំងអស់, ជាអ្នកមានសីលធម៌គួរជាទីជ្រះថ្លាដល់ភ្នែកអ្នកផង ក៏ហៅថា "អ្នកសប្បុរស" ៗ

ពាក្យថា "សប្បុរស" នេះមកអំពីបាលីថា "សន្តៈ" មានអត្ថឲ្យប្រែបាន ៦ យ៉ាង គឺ:

១ — សន្តៈ ប្រែថា "មាន, មានគ្រប់គ្រាន់" ដូចបាលីថា

ទ្វេ មេ ភិក្ខវេ បុគ្គលា <u>សន្តោ</u> សំវិជ្ជមានា ទុល្លភា

លោកស្មឹ “ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួកនេះ មានក្នុងលោក គេរកបានដោយក្រ” ។

២ – សន្ត: ប្រែថា “មនុស្សល្អ” ដូចបាលីថា សន្តោ ហវេ សព្ភិ បវេទយន្តិ “ពួកមនុស្សល្អ រមែងនិយាយ នឹងមនុស្សល្អ” ។

៣ – សន្ត: ប្រែថា “ហត់នឿយ” ដូចបាលីថា ទីឃំ សន្តស្ស យោជនំ “យោជន៍វែង របស់បុគ្គលអ្នកហត់នឿយ” ។

៤ – សន្ត: ប្រែថា “រលត់” ដូចបាលីថា អយញ្ច វិតក្កោ អយញ្ច វិចារោ សន្តា ហោន្តិ “វិតក្កនេះក្តី វិចារនេះក្តី ជាធម៌ រលត់ហើយ” ។

៥ – សន្ត: ប្រែថា “ល្អិតល្អ” ដូចបាលីថា អធិគតោ ខោ ម្យាយំ ធម្មោ សន្តោ បណីតោ “ធម៌នេះ ជាធម៌ល្អិតល្អ ប្រសើរ ដែលតថាគតត្រាស់ដឹងហើយ” ។

៦ – សន្ត: ប្រែថា “ស្ងប់រម្ងាប់” ឬ “រៀបរយ” ដូចបាលីថា ឧបសន្តស្ស សទា សតិមតោ “បុគ្គលអ្នកស្ងប់រម្ងាប់ (ឬ រៀបរយ) មានស្មារតីគ្រប់កាលទាំងពួង” ។

ពាក្យថា “អ្នកសប្បុរស” ក្នុងទីនេះ សំដៅយកមនុស្សល្អ ឬ មនុស្សចិត្តជា ដែលមានសីលធម៌ មានសណ្តាប់ធ្នាប់ដោយកាយ វាចាចិត្ត

ជាសុចរិត អាចឲ្យអ្នកផងគួរសេពគប់ទទួលស្គាល់បាន ។ បុគ្គលប្រួបប្រួម ទាក់ទងនឹងគ្នាដោយករណីយកិច្ចផ្សេងៗ តាំងពីពីរនាក់ឡើងទៅ ទោះបីជាតិជាមួយគ្នាក្តី ជាតិផ្សេងពីគ្នាក្តី គេហៅថា **សហភាព** ប្រែថា "ការនៅប្រួមជាពួកជាមួយគ្នា" ។ ពួកជនក្នុងសហភាពនោះៗ, កាលបើគ្មានមនុស្សសប្បុរសនឹងមនុស្សល្អហើយ, ទោះបីប្រកបកិច្ចការអ្វីមួយក៏មិនបានសម្រេចផលដោយល្អទេ ច្រើនតែមានទុបសគ្គស្ទាក់ដំណើរសេចក្តីចម្រើនទៅវិញ ។ មែនពិត, មនុស្សទាំងអស់ក្នុងលោក ដែលមានកិច្ចការត្រូវធ្វើ សុទ្ធតែទាក់ទងដោយពួកគណៈ បើមិនច្រើនក៏តិច, ព្រោះថាមនុស្សយើងនឹងនៅតាមទំនើងខ្លួនម្នាក់ឯង ដោយមិនបាច់ពឹងអាស្រ័យនឹងអ្នកណាមួយនោះពុំបានឡើយ ។ តាមធម្មតា មនុស្សក្នុងលោកនេះតែងមានអធ្យាស្រ័យ មានគំនិតផ្សេងៗគ្នា គឺមនុស្សខ្លះមានអធ្យាស្រ័យល្អគួរគប់រកគួររាប់អាន មានចិត្តទូលាយផ្សាយប្រយោជន៍ដល់ជាតិសាសនារបស់ខ្លួន មានសុចរិតធម៌ស្មោះត្រង់ល្អ ប្រកបដោយមេត្តាករុណាចំពោះបុគ្គលទូទៅពុំរើសមុខ មិនចំពោះតែត្រកូលត្រសារខ្លួនឡើយ, បុគ្គលបែបនេះ លោកហៅថា សប្បុរស ។ មនុស្សសប្បុរសកាលបើមាននៅក្នុងគណៈណា ក្នុងសមាគមណា ឬក្នុងទីប្រជុំណា រមែងបណ្តាលឲ្យសម្រេចផលល្អ ញុំាងប្រយោជន៍ឲ្យសម្រេចដោយសុវត្ថិភាព ដល់គណៈនោះ ដល់សមាគមនោះ ដល់ទីប្រជុំនោះ ដោយពិតពុំខាន ។

ព្រោះហេតុនោះ ការសេពគប់ត្រូវតែជ្រើសពិនិត្យរកបុគ្គលដែលល្អដោយហ្មត់ចត់ទើបជាការល្អ ។ មនុស្សខ្លះមានអធ្យាស្រ័យគ្រោតគ្រោតអាក្រក់ គ្មានសុចរិតធម៌គិតតែប្រយោជន៍ផ្ទាល់ខ្លួន មានចិត្តឫស្យាឈ្នានិសផិះផាន់រំលោភរកប្រយោជន៍ទាំងបំពាន គិតខាងតែបានប្រយោជន៍មកខ្លួនដោយផ្លូវទុច្ចរិត មានចិត្តប្រាសចាកមេត្តាករុណា ក្សត់ចិត្តនឹងមនុស្សជាតិផងគ្នា; បុគ្គលបែបនេះ លោកហៅថា អសប្បុរសគ្រោតគ្រាតបំផុត ។ ក្នុងប្រទេសណាឬក្នុងសមាគមណា បើមានមនុស្សអសប្បុរសនៅលាយឡំផង ប្រទេសនោះ សមាគមនោះនឹងវិនាសហិនហោចខ្សត់ខ្សោយចុះជាលំដាប់ ។

មួយទៀត ពាក្យថា “សប្បុរស” សំគាល់យកមនុស្សមានសុចរិតធម៌ ។ សុចរិតធម៌ ទុកដូចជាសញ្ញាប័ត្រមួយដ៏ប្រសើរបំផុត, កាលបើបុរសស្ត្រីណាមួយ មានសុចរិតធម៌, បុរសស្ត្រីនោះគេហៅថា មនុស្សសប្បុរស ។ សុចរិតធម៌ជាគ្រឿងសំគាល់មួយ សម្រាប់ទាយបានថាជាសប្បុរស ដែលផ្ទុយគ្នាអំពីអសប្បុរសដោយពិត ព្រោះថាធម៌របស់សប្បុរសនឹងអសប្បុរសឃ្លាងពីគ្នាដូចទិសខាងកើតនឹងទិសខាងលិច ។

ព្រះពុទ្ធសាសនា ជាសាសនាដែលសម្បូរដោយសុចរិតធម៌នេះច្រើនជាទីបំផុត, អ្នកដែលបានសន្សំសុចរិតធម៌ រមែងបាននូវសេចក្ដីសុខទាំងបច្ចុប្បន្នទាំងបរលោក ។ សុចរិតធម៌ជាមូលហេតុនៃសេចក្ដីសុខ ផ្ទុយគ្នា

នឹងទុច្ចរិត, ចំណែកឯទុច្ចរិត ក៏ជាមូលហេតុនៃសេចក្ដីទុក្ខ; ឬថ.សុចរិត ជាហេតុនៃសន្តិសុខ, ទុច្ចរិតជាហេតុនៃអសន្តិសុខ យ៉ាងនេះវិញក៏បាន ។ រដ្ឋាភិបាលក្នុងប្រទេសនីមួយៗ ក៏ត្រូវគិតអំពីសុចរិតនឹងទុច្ចរិតដែលតែងតែមាននៅក្នុងក្រសួងឲ្យណាស់ ទើបរំលាងអយុត្តិធម៌ទៅបាន ។

ពុទ្ធសាសនាឈ្មោះថា សភាសន្តិសុខផ្លូវធម៌ ដែលមានព្រះសម្មា-សម្ពុទ្ធជាប្រធានរបស់សភា ។ សភាសន្តិសុខក្នុងលោក ក្រៅអំពីព្រះពុទ្ធសាសនា ឈ្មោះថា សភាសន្តិសុខផ្លូវលោក ជាសភាសម្រាប់រក្សាការពារប្រទេស ដើម្បីកុំឲ្យកើតសង្គ្រាមរវាងប្រជាជនក្នុងលោក ឬកុំឲ្យមានការចលាចលប៉ុណ្ណោះ; ទោះបីមានសភាសន្តិសុខផ្លូវលោក ព្រមទាំងមានគ្រឿងអាវុធជាជំនួយយ៉ាងនេះហើយ ក៏គង់តែកើតសង្គ្រាមឡើងបានក្នុងកាលខ្លះពុំខាន, ដូចយ៉ាងសន្និបាតជាតិនៅប្រទេសអឺរ៉ុបក្ដី អង្គការសហប្រជាជាតិនៅប្រទេសអាមេរិកក្ដី សុទ្ធតែជាសភាសន្តិសុខសម្រាប់រំលត់ភ្លើងទុក្ខក្នុងលោក បានផលខ្លះពិតមែនហើយ, តែថាសភាសន្តិសុខនេះ សម្រាប់រក្សាតែសេចក្ដីសុខខាងក្រៅតែម្យ៉ាង ។ ចំណែកខាងព្រះពុទ្ធសាសនា ជាសភាសន្តិសុខផ្លូវធម៌ដ៏ប្រសើរបំផុត ព្រោះអាចរម្ងាប់សត្វបានទាំងខាងក្នុងទាំងខាងក្រៅ ហើយនាំអ្នកស-មាជិកឲ្យបានមគ្គផលនិព្វាន មានកម្មវិធីដ៏ជ្រាលជ្រៅសុខុមភាពច្រើនប្រការណាស់ ហើយគួររាប់ថាជាសភាចាស់ទុំ មានអាយុជីវិតវែងឆ្ងាយ

ណាស់មកហើយ គួរយើងជាពុទ្ធបរិស័ទរៀបចំជួសជុលឲ្យមានរបៀបឡើង ៗ មួយទៀត សភាសន្តិសុខនៃព្រះពុទ្ធសាសនានេះមិនបាច់ប្រើគ្រឿងការពារយុទ្ធភ័ណ្ឌ ដូចសភាសន្តិសុខផ្លូវលោកឡើយ ៗ ចំណែកខាងគ្រឿងការពារគុណផ្លូវព្រះពុទ្ធសាសនាក៏មានប្រើដែរ តែជាការពារដោយនាមធម៌ សម្រាប់តស៊ូនឹងបច្ចាមិត្តគឺកិលេសមានលោភៈជាដើម មិនមែនការពារមានរូបដែលធ្វើអំពីវត្ថុផ្សេង ៗ មានដែកជាដើមនោះទេ ៗ

ការពារគុណព្រះពុទ្ធសាសនាមាន ៣ យ៉ាង គឺ:

១ – **សុតាវុធ** ការស្តាប់, ការរៀន, ការប្រតិបត្តិធម៌ដោយគោរព, នេះឯងទុកជាការពារសម្រាប់ព្រះពុទ្ធសាសនា ៗ

២ – **បវិវេកាវុធ** ការនៅដោយស្ងប់ស្ងាត់ចាកពួកគណៈ, ស្ងប់ស្ងាត់ចាកកិលេសមានរាគៈជាដើម ឬស្ងប់ស្ងាត់ចាកនីវរណធម៌ទាំងឡាយមានកាមឆន្ទៈជាដើម, នេះឯងទុកជាការពារសម្រាប់ព្រះពុទ្ធសាសនា ៗ

៣ – **បញ្ញាវុធ** ការពិចារណាពរកហេតុផលរបស់សេចក្តីទុក្ខនិងហេតុផលនៃលក្ខណៈ ៣ យ៉ាង មានអនិច្ចលក្ខណៈជាដើមរបស់បញ្ចក្ខន្ធ; នេះឯងទុកជាការពារសម្រាប់ព្រះពុទ្ធសាសនា ៗ មួយទៀតព្រះពុទ្ធសាសនាមានដំបូន្មានដ៏ល្អ ៗ ទៀតជាច្រើនណាស់ សម្រាប់

ប្រៀនប្រដៅប្រជាជនដែលមិនទាន់មានសុចរិតធម៌ ឲ្យមានសុចរិតធម៌ឡើង, ដែលមានឋានៈជាអសប្បុរសអាចធ្វើឲ្យទៅជាមនុស្សសប្បុរសឡើងបាន, ទាំងនេះឯងក៏ទុកជាការុធដ៏ប្រសើរដែលនាំមនុស្សឲ្យក្លាយជាសប្បុរស ៗ

មួយទៀត សភាគឺទីប្រជុំនិយាយការឯណាដែលមិនមានមនុស្សជាសមាជិកសប្បុរស, ទីនោះមិនឈ្មោះថាជាសភាឡើយ; សមដូចពុទ្ធភាសិតក្នុងសំយុត្តនិកាយថា:

នេសា សភា យត្ថ ន សន្តិ សន្តោ
សន្តោ ន តេ យេ ន វទន្តិ ធម្មំ
រាគញ្ច ទោសញ្ច បហាយ មោហំ
ធម្មំ វទន្តា ច ភវន្តិ សន្តោ ៗ

ប្រែថា "មនុស្សសប្បុរសទាំងឡាយ មិនមានក្នុងពួកណា, ពួកនោះមិនឈ្មោះថាជាសភាទេ; ពួកជនណាមិននិយាយធម៌, ពួកជននោះមិនឈ្មោះថាសប្បុរសទេ; លុះតែពួកជនដែលលះបង់នូវរាគៈ ទោសៈ មោហៈ ហើយនិយាយនូវធម៌ ទើបឈ្មោះថា "អ្នកសប្បុរស" ៗ

ពុទ្ធភាសិតនេះ វិនិច្ឆ័យអំពីសភារបស់សមាជិកសប្បុរសនិងអសប្បុរស ព្រមទាំងវិនិច្ឆ័យអំពីបុគ្គលដែលគួរហៅថា មនុស្សសប្បុរស ៗ

(មានត)

# សប្បុរិសធម្មគាថា

## ព្រះទេពសត្ថាសួរ-ហាយ រៀបរៀង

(ត-ចប់)

---

ទីណាឬប្រទេសណាដែលសម្បូរដោយមនុស្សសប្បុរស, ទីនោះ ប្រទេសនោះរមែងប្រព្រឹត្តទៅដើម្បីសេចក្ដីសុខ សេចក្ដីចំរើន ដោយ ពិតប្រាកដឥតអាក់; កុំថាឡើយដល់ទៅសង្គ្រាម សូម្បីតែចោរលួចប្លន់ ក៏ពុំមានឡើយ ។ មួយវិញទៀត ធម៌របស់សប្បុរស ឬធម៌សម្រាប់ សំគាល់ឲ្យដឹងថាអ្នកនេះជាមនុស្សសប្បុរសឬអសប្បុរសនោះ លោក ហៅថា សប្បុរិសធម៌ មាន ៧ យ៉ាង :

១– **ធម្មញ្ញុតា** សេចក្ដីដឹងធម៌ សំដៅយកការដឹងហេតុនៃ សេចក្ដីសុខទុក្ខ ហើយកាន់យកហេតុនៃសុខលះបង់ហេតុនៃទុក្ខចេញ ។

២– **អត្ថញ្ញុតា** សេចក្ដីដឹងអត្ថ គឺដឹងផលនៃសេចក្ដីសុខទុក្ខ ហើយតាំងចិត្តសន្ដោស គឺត្រេកអរតាមមានតាមបាន ។

៣– **អត្តញ្ញុតា** សេចក្ដីដឹងខ្លួន គឺដឹងថាអាត្មាអញមានជាតិ ត្រកូលថោកទាប ឬខ្ពង់ខ្ពស់យ៉ាងណា ហើយប្រព្រឹត្តខ្លួនឲ្យសមគួរ មិន ឲ្យជាទំនាស់ដល់អ្នកដទៃ ។

៤ – **មត្តញ្ញុតា** សេចក្តីដឹងប្រមាណ គឺដឹងច្បាស់ក្នុងការស្វែងរក, ក្នុងការទទួលយក, ក្នុងការបរិភោគប្រើប្រាស់ ចំពោះវត្ថុផ្សេងៗ ហើយការចេះលៃលកឲ្យសមគួរដល់ប្រមាណ, ប្រកបដោយធម៌សន្តោស សមគួរដល់ប្រទេសជាតិរបស់ខ្លួន, មិនស្ទុះស្ទារមិនលោភឡើង ឲ្យហួសហេតុពេកខុសទំនង ដែលនាំឲ្យខូចតម្លៃកិត្តិយសរបស់ជាតិសាសនារបស់ខ្លួន ព្រោះតែនយោបាយរបស់គេនោះឡើយ ។

៥ – **កាលញ្ញុតា** សេចក្តីដឹងកាល គឺដឹងថាកាលវេលានេះគួរប្រកបកិច្ចការនោះៗ, កាលវេលានេះជាកាលមិនគួរប្រកបកិច្ចការនោះៗទេ ។

៦ – **បរសញ្ញុតា** សេចក្តីដឹងបរិសទ្យ គឺដឹងថាប្រជុំជននេះមានឋានៈបែបនេះមានកិរិយាបែបនេះ ហើយប្រព្រឹត្តខ្លួនតម្រូវឲ្យសមគួរដល់អធ្យាស្រ័យនៃបរិសទ្យនោះ ។

៧ – **បុគ្គលបរោបរញ្ញុតា** សេចក្តីដឹងបុគ្គលជាន់ខ្ពស់-កណ្តាល-ទាប គឺដឹងថាបុគ្គលនេះជាមនុស្សសប្បុរស គឺមនុស្សល្អដែលគួរសេពគប់, បុគ្គលនេះជាមនុស្សអសប្បុរស គឺមនុស្សអាក្រក់ដែលមិនគួរសេពគប់ជាដើម ។

សប្បុរិសធម៌ ៧ ប្រការនេះ ទុកជាត្រាប្រថាប់ឬជាសញ្ញាប័ត្រមួយ សម្រាប់ឲ្យទាយបានថា : បើនរណាមានធម៌ ៧ ប្រការនេះ នរៈនោះ

ទើបឈ្មោះថាជាមនុស្សសប្បុរសដោយពិត, បើបុគ្គលណាមិនមានធម៌ ៧ ប្រការនេះទេ, បុគ្គលនោះក៏បានឈ្មោះថាជាមនុស្សអសប្បុរស ។

មនុស្សយើងដោយប្រក្រតីរមែងមានធម៌ទាំងនេះតាំងនៅក្នុងខ្លួនខ្លះមិនខាន, បើមិនមានច្រើនក៏គង់មានតិច ៗ អ្នកដែលមានធម៌នេះតិចមិនគ្រប់គ្រាន់ក្នុងសន្តាន រមែងទៅជាមនុស្សមានសេចក្ដីអង់អាចតិច, មានសេចក្ដីសុខសេចក្ដីចំរើនក៏តិចតាមលំដាប់ ៗ អ្នកដែលមានធម៌ទាំងនេះច្រើនក្នុងសន្តាន រមែងបានជាមនុស្សមានសមត្ថភាព, ថ្លៃថ្នូរ, មោះមុតអង់អាចច្រើន ធ្វើប្រយោជន៍ដល់ខ្លួននឹងជាតិសាសនារបស់ខ្លួនក៏បានច្រើន; ទាំងសេចក្ដីសុខសេចក្ដីសរសើរនិងកេរ្តិ៍ឈ្មោះយសស័ក្ដិក៏មានច្រើន ៗ

ព្រះពុទ្ធសាសនា ជាបដិបទាឲ្យកើតសន្តិសុខដោយសុតសុភាព សម្រាប់ដឹកនាំមនុស្សឲ្យទៅជាសប្បុរស ៗ ឯពាក្យថា “សន្តិសុខ” នេះសំដៅយកសេចក្ដីសុខសាន្ត ទាំងលោកនេះនិងលោកខាងមុខ ៗ មួយទៀត សេចក្ដីសុខនេះមាន ២ យ៉ាង គឺ សេចក្ដីសុខដែលកើតអំពីការស្ងប់រម្ងាប់ ពាកទុក្ខទោសពៃរ៍ភ័យសត្រូវ ជាសេចក្ដីសុខរបស់ប្រទេសជាតិ របស់មនុស្ស របស់ទេវតា ដែលនៅលាយឡំដោយទុក្ខខ្លះ ហៅថា សាមិសសុខ ១; សេចក្ដីសុខស្អាតបរិសុទ្ធដែលកើតអំពីការស្ងប់រម្ងាប់ពាកកិលេស ពាកបញ្ចក្ខន្ធ គឺជាសុខដែលមិនលាយឡំដោយទុក្ខទោសពៃរ៍តទៅទៀត បានដល់សេចក្ដីសុខរបស់ព្រះនិព្វាន នេះ

លោកហៅថា និរាមិសសុខ ១ ។ ព្រះពុទ្ធសាសនា តែងឲ្យសម្រេចផលទាំងឡាយ គឺសុខ ២ ប្រការនេះឯង ។

ព្រះពុទ្ធសាសនា ប្រៀបដូចជាផ្ទះផ្សារមួយខ្នង ដែលមានទំនិញល្អៗច្រើន ហើយជាទំនិញសុទ្ធតែវត្ថុបរិសុទ្ធ មិនមែនជារបស់ក្លែងក្លាយ ឬមានពិសពុលក្តៅក្រហាយ ដូចកនផ្សារគឺសាសនាឯទៀតៗនោះទេ ។ ផ្សារគឺពុទ្ធសាសនានេះ បើកលក់ចំពោះតែរបស់ណាមួយដែលមិនជាសត្រូវ ។ ទំនិញដែលបរិសុទ្ធនោះ គឺមគ្គប្រកបដោយអង្គ ៨ ប្រការ មានសម្មាទិដ្ឋិជាដើម នឹងកុសលធម៌ទាំងឡាយឯទៀតៗជាច្រើន, គួរតែប្រជាជនក្នុងលោកចូលមកទិញទំនិញល្អៗនោះតាមត្រូវការ ។ ព្រះពុទ្ធសាសនា មានបញ្ញត្តិសិក្ខាបទជាសាធារណៈដល់មនុស្សនឹងមនុស្សផងគ្នា ព្រមទាំងដល់មនុស្សនឹងសត្វតិរច្ឆាន ឥតមានរើសជាតិឡើយ, ទោះបីមនុស្សក៏ត្រូវមានធម៌សុចរិតក្នុងរវាងសត្វតិរច្ឆាន ។ ព្រោះសត្វតិរច្ឆានមានជីវិតជាទីស្រឡាញ់ មានមេ មានបា មានកូន ជាទីស្រឡាញ់របស់វាយ៉ាងណា ; មនុស្សយើងក៏យ៉ាងនោះដែរ ។ សាសនាឯទៀតៗក្រៅពីនេះ ឬច្បាប់បញ្ញត្តិរបស់ប្រទេសទាំងឡាយក្នុងលោក ច្រើនតែបញ្ញត្តគឹងរឹងតែក្នុងរវាងមនុស្សនឹងមនុស្ស ដូចយ៉ាងផ្លូវបាណាតិបាត ឬអទិន្នាទានជាដើម ចំពោះតែមនុស្សផងគ្នា, ត្រង់មនុស្សសម្លាប់តិរច្ឆានឬលួចប្លន់ដណ្តើមស៊ុតសត្វតិរច្ឆានកូនទៅសត្វតិរច្ឆាន មិនឃើញមានបញ្ញត្តិផងឡើយ ។

បុគ្គលជាមនុស្សជាតិណាមួយ កាន់ធម៌សុចរិតទៀងទាត់ពិតត្រង់ក្នុង ការរបស់ប្រទេស របស់សាសនា ទាំងរវាងមនុស្សនឹងមនុស្សដូចគ្នា, ទោះបីជាមនុស្សជាន់ទាបឬជាន់ខ្ពស់ ក៏មិនត្រូវប្រមាថមើលងាយបៀតបៀនរើបជាន់ដល់គ្នានឹងគ្នាទេ, ទាំងមនុស្សក៏ត្រូវកាន់ធម៌សុចរិតចំពោះតិរច្ឆានផងដែរ ។ បុគ្គលអ្នកកាន់ធម៌តាមបញ្ញត្តិនៃព្រះពុទ្ធសាសនាដូច្នេះ ហៅថា សប្បុរស ។ មនុស្សសប្បុរសនេះ ច្រើនមានតែក្នុងព្រះពុទ្ធ-សាសនា ។ អ្នកដែលកាន់ធម៌សុចរិតរើសមុខដោយការថា ខ្លួនអញជាមនុស្សជាន់ខ្ពស់, ជាអ្នកមានយសស័ក្តិអំណាច, ជាមនុស្សមានកំឡាំងទ្រព្យធនច្រើន, ជាមនុស្សមានឧបាយកិច្ចកលច្រើន ហើយសង្កត់សង្កិនបៀតបៀនមនុស្សដែលថោកទាប, បៀតបៀនមនុស្សដែលឥតយសស័ក្តិ មើលងាយមនុស្សដែលក្រទាល់ទ្រព្យសម្បត្តិ, បោកប្រាស់បំបាត់មនុស្សដែលល្ងង់ខ្លៅដែលគ្មានឧបាយ; អ្នកដែលមានសេចក្តីប្រមាថពាយងាយដូច្នេះ ទោះបីបន្ទំខ្លួនទៅក្នុងសាសនាក៏ហៅថា អសប្បុរស ដែរ ។

ពណ៌នាមកថាអំពីសប្បុរសធម្មកថា ក៏សមគួរដល់វេលា សូមសន្មតបញ្ចប់តែប៉ុណ្ណោះ ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ ទាណិនោ ។

សត្វទាំងឡាយ ដែលដល់នូវទុក្ខ សូមឲ្យជាអ្នកបាត់ទុក្ខទៅ !

ដែលដល់នូវភ័យ សូមឲ្យបាត់ភ័យទៅ ! ដែលដល់នូវសេចក្ដីសោក សូមឲ្យបាត់សោកទៅ !

រតនត្តយតេជេន គារោ្ឋជវឌ្ឍកសិនោ

វុឌ្ឍី វិរុឡ្ហី បវេបុល្ល សត្តិការញ្ញ ញាណជា ។

ដោយតេជៈនៃព្រះរតនត្រ័យ សូមឲ្យប្រជាជនទាំងឡាយអ្នកកើតនៅក្នុងកម្ពុជរដ្ឋ ដល់នូវការលូតលាស់ចំរើនទីនឹងសន្តិភាព កុំបីឃ្លៀងឃ្លាតក្លាយទៅជាប្រការដទៃឡើយ ។

ចប់

ធម៌ស្អាងខ្លួនបីយ៉ាង:

ពូជត្រកូល, ទទួលឧកាស, ឧបាគតំ ;
ត្រកូលឧត្តមាដោយសន្សំអប់រំល្អ,
ទទួលឧកាសដោយមនោស្អាតសុវត្ថ,
ឧបាគតកដោយចំបរប្រព្រឹត្តិការ ។
ធម៌ ៣ នេះគុណវិសេសសានសួស្ដិ៍
ដល់ប្រុសស្រីក្នុងលោកិយឲ្យអស្ចារ្យ
ជាធម៌ពិតជួយប្រសិទ្ធិ៍ដោតសន្ធារ
ឲ្យបាវរពស្ទាពរទ្រទ្ធស់ឡើង ។

យូរ — ស៊ុន